ការផ្លោះទៅរកភាពងងឹត

ការផ្លោះទៅរកភាពងងឹត

ការបោះឆ្នោត នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៨ ជាការផ្លោះ មានហេតុផល នៃអំណាចផ្តាច់ការ។ វាជាការបន្តធម្មតា នៃជម្រៃ នៃបញ្ញាខ្មែរ នៅចំពោះមុខបញ្ហាជាតិធំៗ ដែលពួកអ្នកនយោបាយខ្មែរត្រប់និន្នាការ ផៀសវាងប្រទល់ ហើយនាំគ្នាសម្ងំរស់នៅក្នុងផាសុក នៃខ្លួនសព្វគ្នា។ ផាសុក នៃគណបក្សកាន់អំណាច គឺ រំលាយបក្សប្រឆាំងចម្បង ដោយប្រើវិធីទុរយស ដែលនាំបន្ទាប នូវតម្លៃបញ្ញាខ្លួនឯងកាន់តែទាបទៅៗ លើឆាកជាតិ និង អន្តរជាតិ។ រីឯ ផាសុក នៃគណបក្សប្រឆាំងជាអ្នករងគ្រោះ វិញ គឺ ស្វែងរកជម្រងអន្តរជាតិ ហើយសម្ងំដេកចាំចម្លើយ ដែលនាំអោយ ដែនតស៊ូនយោបាយខ្លួន នៅក្នុងស្រុករួញទៅៗ មកត្រឹមតែជាដុំ នៃសេចក្តីអស់សង្ឃឹម ម្លោះហើយកើតជា បដ្ឋនាលិខិត នៃពួកអ្នកដឹកនាំបក្សមួយក្តាប់ ថ្វាយជូនព្រះមហាក្សត្រ សូមព្រះរាជអន្តរាគមន៍ ដែលវាមិនស្របនឹង មនោគតិ នៃយុទ្ធនាការ នៃម្រាមដៃស្អាត របស់គណបក្ស ហើយ យុទ្ធនាការនោះ វាផ្ទុយស្រឡះពី ព្រះរាជសារ ដល់ប្រជាពលរដ្ឋ អោយទៅបោះឆ្នោត។ នៅពេលដែលភាពល្ងៃល្ងើ មានកំរិតបែបនឹង គេអាចមានការសង្ស័យ ទៅលើ ឋានៈបញ្ញា នៃពួកហត្ថលេខី។

ការផ្ទោះទៅរកភាពងងឹត

ដូច្នេះ តើវានឹងអាចមានដំណោះស្រាយ ចេញពីបញ្ហា ដូចម្តេចបាន បើ គូប្រឆាំងគ្នា សុទ្ធតែជាអ្នកអតិ: ពួកអ្នកកាន់អំណាច គឺឈរលើគំនិត « អញ្ញនិយម » ចំណែកក្រុមពួកអ្នកប្រឆាំង គឺឈរលើគំនិត « ចាញ់និយម ដឹកនាំដោយវប្បធម៌សន្ទនា »។ ប្រជួបគ្នា នៃគំនិត អញ្ញនិយម និង ចាញ់និយម លុះជានិច្ចទៅរកដំណោះស្រាយ នៃការសម្រុះសម្រួលគ្នា ជាសម្ងាត់ ដើម្បីចែកប្រយោជន៍គ្នា ដូចមានកើតឡើងក្រោយពីការបោះឆ្នោតរាល់ដង តាំងពីអាណត្តិរដ្ឋសភាទី១មកម្លេះ។ សួរថា ការសម្រុះសម្រួលបែបនេះ តើវាដែលនាំមក នូវប្រយោជន៍ ដល់ជាតិម្តងណាដែរ ?

បោះឆ្នោត នៅពេលខាងមុខនេះ គឺ ជាដំណើរលោតផ្លោះ ឆ្លងនូវភាពសម្ងាត់ ទៅរកភាពងងឹត ព្រោះនៅក្នុងភាពងងឹត វាងាយស្រួល ចំពោះពួកអ្នកកាន់អំណាច អាចទិញដូរ ពួកជនខ្មែរអតិ, សព្វថ្ងៃ វាមានច្រើនណាស់នៅក្នុងសង្គម, ដើម្បី ប៉ះរើប្រយោជន៍ នៃខ្លួន។ ចំពោះ ពួកអ្នកផ្តាច់ការ, ដំណើរនេះ ជាការផ្ទាស់ នៃពួកអ្នកប្រឆាំងបោកប្រាស ដាក់ជំនួសវិញ នូវពួកអ្នកប្រឆាំងអាមាត្រ ដើម្បី យកឈ្នះប្រជាពលរដ្ឋខ្មែរ ដែលស្រឡាញ់លទ្ធិប្រជាធិតេយ្យ។ ដូច្នេះ ការបោះឆ្នោតលើកនេះ ជាការប្រទល់ក្នាផ្ទាល់ រវាង សតិសម្បជញ្ញៈ នៃប្រជាពលរដ្ឋ នឹងអំណាចផ្តាច់ការ។ នៅក្នុងភាពងងឹត វាប្រាកដ ជានាំអោយភ្នែក នៃប្រជាពលរដ្ឋ ឥតអាចមើលឃើញអ្វីបាន តែវាមិន

ការផ្ទោះទៅរកភាពងងឹត

អាចបំភ្លាំង នូវសតិសម្បជញ្ញៈ នៃគាត់បានឡើយ។ តាមវិធីទុរយស គណបក្សកាន់អំណាច វាធ្លាស់ជាប្លន់អំណាចបានងាយស្រួលពិត តែជាជ័យជំនះ បំបែកសង្គមជាតិប៉ុណ្ណោះ។ សន្តិភាព នៅក្នុងសង្គមបែកបាក់បែបនេះ វាដូចជា សេចក្តីសុខ នៃពួកអ្នកជក់អាភៀន ពោលថា ជាសេចក្តីសុខក្នុងអារម្មណ៍ តែវាបំផ្លាញ នូវសព្វាង្គកាយ និង វិញ្ញាណ ជាមនុស្ស។ សង្គមខ្មែរ ដែលពួកអ្នកផ្តាច់ការសព្វថ្ងៃ គេហៅថា សង្គមកម្ពុជា, ពោលថា ខ្មែរលែងមានលក្ខន្តិកៈជាម្ចាស់ស្រុក, វាប្រែក្លាយជាសង្គមងងឹត សំរាប់ប្រព្រឹត្ត នូវអំពើទុច្ចរិតគ្រប់បែបយ៉ាង។ ដូច្នេះ នៅសល់តែសតិសម្បជញ្ញៈ នៃពលរដ្ឋម្នាក់ៗ នៅពេលបោះឆ្នោតខាងមុខនេះ អាចនឹងបំភ្លើ នូវផ្លូវដើរទៅរកប្រយោជន៍ជាតិខ្មែរបាន។